**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

លេខ ៣៤៨ កសក

រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១៦

**សូមគោរពជូន**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
**នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**

**កម្មវត្ថុ** ៖របាយការណ៍ប្រចាំសប្តាហ៍ស្តីពី សភាពការណ៍ល្បឿនការងារប្រមូលផលដំណាំរដូវវស្សាឆ្នាំ២០១៥ និងល្បឿនការងារបង្កបង្កើនផលដំណាំរដូវប្រាំងឆ្នាំ២០១៥-២០១៦។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទសូមអនុញ្ញាតជម្រាបជូន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ជាទីគោរពដ៏ខ្ពង់ខ្ពស់មេត្តាជ្រាប អំពីសភាពការណ៍ល្បឿនការងារប្រមូលផលដំណាំរដូវវស្សាឆ្នាំ២០១៥ និងល្បឿនការងារបង្កបង្កើនផលដំណាំរដូវប្រាំងឆ្នាំ២០១៥-២០១៦ គិតត្រឹមថ្ងៃទី២០ ខែមករា ឆ្នាំ២០១៦ មានដូចតទៅ ÷

## I. ល្បឿនការងារប្រមូលផលស្រូវរដូវវស្សាឆ្នាំ២០១៥ (ដូចមានតារាងជូនភ្ជាប់) ÷

ផ្ទៃដីអនុវត្តបានសរុបចំនួន២.៥៦១.៩៥៧ហ.ត ស្មើនឹង៩៩,៨០ភាគរយ នៃផែនការ២.៥៦៧.១៣០ហ.ត តិចជាងឆ្នាំមុនចំនួន ២.៦១៥ហ.ត ក្នុងនោះ ការងារប្រមូលផលស្រូវរហូតដល់សប្តាហ៍នេះ សម្រេចបានលើផ្ទៃដីចំនួន ២.៥៣០.១១៨ហ.ត (សប្តាហ៍មុនចំនួន២.៤៩១.១២៩ហ.ត) លើសឆ្នាំមុន១.២២១ហ.ត ដោយទទួលបានបរិមាណផលសរុបចំនួន៧.០៥៣.៨៨៨តោន លើសឆ្នាំមុន ៤៣.២៨៨តោន។ ទិន្នផលមធ្យម២,៧៨៨តោន/ហ.ត (សប្តាហ៍មុនចំនួន ២,៧៦៤ត/ហ.ត) លើសឆ្នាំមុន១៦គ.ក្រ/ហ.ត។

## II. ល្បឿនការងារបង្កបង្កើនផលស្រូវរដូវប្រាំងឆ្នាំ២០១៥-២០១៦ (ដូចមានតារាងជូនភ្ជាប់) ÷

ក- ការងារដាំដុះ ÷

- លទ្ធផលភ្ជួររាស់រៀបចំដីសម្រេចបានចំនួន៥២៤.០៨៤ហ.ត លើសឆ្នាំមុនចំនួន៦.០៦៤ហ.ត ក្នុងនោះ ភ្ជួររាស់ដោយគោ ក្របីចំនួន១៧.០៩៣ហ.ត ស្មើនឹង៣,២៦% និងដោយគ្រឿងយន្តចំនួន៥០៦.៩៩១ហ.ត ស្មើនឹង៩៦,៧៤%
- សាបបានសរុបចំនួន១.១៤១ហ.ត តិចជាងឆ្នាំមុនចំនួន២.៨៥៨ហ.ត
- ស្ទូងនិងព្រោះសម្រេចបានចំនួន៤៧៣.៣៦៥ហ.ត ស្មើនឹង១១៣,៤៣% នៃផែនការ៤១៧.៣២៥ហ.ត លើសឆ្នាំមុន១៩.៦៩២ហ.ត។

ខ- ល្បឿនការងារប្រមូលផលស្រូវរដូវប្រាំងឆ្នាំ២០១៥-២០១៦ (ដូចមានតារាងជូនភ្ជាប់) ÷

ក្នុងសប្តាហ៍នេះ ការងារប្រមូលផលស្រូវប្រាំងសម្រេចចំនួន ៣១.៤៨៤ហ.ត ស្មើនឹង ៦,៦៥% នៃផ្ទៃដីអនុវត្តបានចំនួន៤៧៣.៣៦៥ហ.ត ដោយទទួលបានបរិមាណផលសរុបចំនួន១៤៥.២៧២តោន ទិន្នផលគិតជាមធ្យមបាន ៤,៦១៤តោន/ហ.ត លើសឆ្នាំមុន៤៨គ.ក្រ/ហ.ត។

## III. ល្បឿនការងារបង្កបង្កើនផលដំណាំរួមផ្សំនិងដំណាំឧស្សាហកម្មរដូវប្រាំងឆ្នាំ២០១៥-២០១៦ (ដូចមានតារាងជូនភ្ជាប់) ÷

ក- ផ្ទៃដីដំណាំរួមផ្សំ អនុវត្តបានចំនួន៦៧.១៣៨ហ.ត ស្មើនឹង១៥៧,២៤% នៃផែនការ៤២.៦៩៨ហ.ត លើសមុន ១៧.៣៥៩ហ.ត។

ខ- ផ្ទៃដីដំណាំឧស្សាហកម្ម អនុវត្តបានចំនួន១១.៧៨៣ហ.ត ស្មើនឹង៥៧,៩៦% នៃផែនការ២០.៣៣១ហ.ត តិចជាងឆ្នាំមុន ៣៥៨ហ.ត។

អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
№ 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia
ទូរស័ព្ទលេខ :(០២៣) ៧២៦ ១២៨/ ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 726 128 / 726 129, Fax : (855) 23 - 217 320

## IV. **សេចក្តីសន្និដ្ឋាន ÷**

ជារួមការងារបង្កបង្កើនផលស្រូវរដូវវស្សាឆ្នាំ២០១៥ ត្រូវបានបញ្ចប់ជាស្ថាពរហើយ។ ជាទូទៅស្រូវវស្សាទទួលបានផលល្អគ្រប់កន្លែង ដោយសារអំណោយផលពីភ្លៀងចុងរដូវ។ មកទល់ពេលនេះ ការងារប្រមូលផលដំណាំស្រូវរដូវវស្សាឈានជិតដល់បញ្ចប់ទូទាំងប្រទេសហើយ គឺនៅសល់តែខេត្តបន្ទាយមានជ័យ និងរាជធានីភ្នំពេញ ប៉ុណ្ណោះដែលបាននិងកំពុងបន្តដំណើរការប្រមូលផលស្រូវនៅឡើយ។ ទន្ទឹមនឹងនោះ ប្រជាកសិករបានបន្តការធ្វើស្រែប្រាំងនិងស្រូវប្រដេញទឹកយ៉ាងមមាញឹក នឹងបានប្រមូលផលស្រូវរដូវប្រាំងជាបណ្តើរៗ។ ទោះបីជួបប្រទះគ្រោះរាំងស្ងួតកណ្តាលរដូវវស្សាក៏ដោយ ក៏ការងារបង្កបង្កើនផលស្រូវរដូវប្រាំងឆ្នាំនេះ សម្រេចបានចំនួន៤៧៣.៣៦៥ហាត ស្មើនឹង១១៣,៤៣% នៃផែនការ៤១៧.៣២៥ហាត លឿនជាងឆ្នាំមុនបើប្រៀបធៀបរយៈពេលដូចគ្នា។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានបន្តធ្វើការអប់រំណែនាំដល់ប្រជាកសិករឲ្យបង្កើនការខិតខំថែទាំដំណាំស្រូវប្រាំង ក៏ដូចជាការថែទាំដំណាំផ្សេងៗទៀតដែរ និងយកចិត្តទុកដាក់លើការគ្រប់គ្រងនិងការប្រើប្រាស់ទឹកឲ្យគត់មត់តាមសារាចរណែនាំលេខ០៩ សរណន ចុះថ្ងៃទី២៣ ខែធ្នូ ២០១៥ របស់រាជរដ្ឋាភិបាល ស្តីពីការចាត់វិធានការថែរក្សាទឹកទុក។ ទន្ទឹមនឹងនេះ ក្រសួងបន្តពង្រឹងវិធានការទប់ស្កាត់ការបាត់បង់បរិមាណនិងគុណភាពស្រូវរដូវវស្សា និងរដូវប្រាំងឆ្នាំ២០១៥-២០១៦ នៅក្នុងនិងក្រោយពេលប្រមូលផល ដើម្បីឲ្យគ្រប់អង្គភាពក្រោមឱវាទនិងមន្ទីរកសិកម្មរាជធានី ខេត្តទូទាំងប្រទេសណែនាំដល់ប្រជាកសិករ ផលិតករ និងអ្នកពាក់ព័ន្ធទាំងអស់ឲ្យអនុវត្តក្នុងស្មារតីយកចិត្តទុកដាក់ខ្ពស់។

អាស្រ័យហេតុដូចបានគោរពរាយការណ៍ជូនខាងលើនេះ ខ្ញុំបាទសូម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ជាទីគោរពដ៏ខ្ពង់ខ្ពស់ មេត្តាជ្រាបដោយក្តីអនុគ្រោះ។

សូម**សម្តេចតេជោ នាយករដ្ឋមន្ត្រី** មេត្តាទទួលនូវសេចក្តីគោរពដ៏ជ្រាលជ្រៅបំផុតអំពីខ្ញុំបាទ។

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

ព្រះរាជាណាចក្រកម្ពុជា * ក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ *

**បណ្ឌិត អ៊ុក រ៉ាប៊ុន**

**ចម្លងជូន ÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ
- គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
- ក្រសួងផែនការ
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

"ដើម្បីជូនជ្រាប"

- ថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

"ដើម្បីជ្រាប"

- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
នាយកដ្ឋានផែនការ និង ស្ថិតិ

# ល្បឿនការងារប្រមូលផលស្រូវរដូវវស្សា ឆ្នាំ ២០១៥

(គិតត្រឹមថ្ងៃទី២០ ខែមករា ឆ្នាំ២០១៦)

| ល.រ | រាជធានី-ខេត្ត | ផ្ទៃដីអនុវត្ត (ហត) | ផ្ទៃដីប្រមូលផល (ហត) | ទិន្នផល (តោន/ហ.ត) | បរិមាណផល (តោន) | ភាគរយ (%) | ថ្ងៃខែរាយការណ៍ |
|---|---|---|---|---|---|---|---|
| 01 | បន្ទាយមានជ័យ | 246,021 | 230,011 | 2.360 | 542,746 | 93.49 | 18-01-2016 |
| 02 | បាត់ដំបង | 290,056 | 279,123 | 2.860 | 798,319 | 96.23 | បញ្ចប់ |
| 03 | កំពង់ចាម | 87,146 | 87,146 | 3.219 | 280,535 | 100.00 | បញ្ចប់ |
| 04 | កំពង់ឆ្នាំង | 122,581 | 122,483 | 2.834 | 347,153 | 99.92 | បញ្ចប់ |
| 05 | កំពង់ស្ពឺ | 112,647 | 112,625 | 3.010 | 339,001 | 99.98 | បញ្ចប់ |
| 06 | កំពង់ធំ | 213,426 | 213,426 | 2.410 | 514,459 | 100.00 | បញ្ចប់ |
| 07 | កំពត | 136,537 | 136,537 | 3.150 | 430,092 | 100.00 | បញ្ចប់ |
| 08 | កណ្ដាល | 35,280 | 35,280 | 3.088 | 108,959 | 100.00 | បញ្ចប់ |
| 09 | កោះកុង | 10,405 | 10,405 | 2.850 | 29,658 | 100.00 | បញ្ចប់ |
| 10 | ក្រចេះ | 32,286 | 32,286 | 2.672 | 86,263 | 100.00 | បញ្ចប់ |
| 11 | មណ្ឌលគិរី | 22,929 | 22,929 | 2.368 | 54,289 | 100.00 | បញ្ចប់ |
| 12 | ភ្នំពេញ | 11,153 | 10,507 | 2.819 | 29,616 | 94.21 | 19-01-2016 |
| 13 | ព្រះវិហារ | 83,388 | 83,388 | 2.738 | 228,303 | 100.00 | បញ្ចប់ |
| 14 | ព្រៃវែង | 268,315 | 268,315 | 2.996 | 803,983 | 100.00 | បញ្ចប់ |
| 15 | ពោធិ៍សាត់ | 108,329 | 105,393 | 3.034 | 319,762 | 97.29 | បញ្ចប់ |
| 16 | រតនគិរី | 26,018 | 26,018 | 2.031 | 52,853 | 100.00 | បញ្ចប់ |
| 17 | សៀមរាប | 186,050 | 185,220 | 2.333 | 432,160 | 99.55 | បញ្ចប់ |
| 18 | ព្រះសីហនុ | 16,614 | 16,614 | 2.750 | 45,689 | 100.00 | បញ្ចប់ |
| 19 | ស្ទឹងត្រែង | 28,689 | 28,689 | 2.600 | 74,591 | 100.00 | បញ្ចប់ |
| 20 | ស្វាយរៀង | 167,946 | 167,658 | 2.650 | 444,294 | 99.83 | បញ្ចប់ |
| 21 | តាកែវ | 197,234 | 197,234 | 3.284 | 647,801 | 100.00 | បញ្ចប់ |
| 22 | ឧត្តរមានជ័យ | 72,000 | 72,000 | 2.300 | 165,600 | 100.00 | បញ្ចប់ |
| 23 | កែប | 3,588 | 3,588 | 3.227 | 11,579 | 100.00 | បញ្ចប់ |
| 24 | ប៉ៃលិន | 5,001 | 4,925 | 2.633 | 12,968 | 98.48 | បញ្ចប់ |
| 25 | ត្បូងឃ្មុំ | 78,318 | 78,318 | 3.233 | 253,215 | 100.00 | បញ្ចប់ |
| សរុប | | **2,561,957** | **2,530,118** | **2.788** | **7,053,888** | **98.76** | |
| តួលេខសប្តាហ៍មុន | | **2,561,957** | **2,491,129** | **2.764** | **6,885,883** | **97.24** | |
| តួលេខឆ្នាំ២០១៤ | | **2,564,572** | **2,528,897** | **2.772** | **7,010,600** | **98.61** | |
| ប្រៀបធៀបឆ្នាំមុន | | **-2,615** | **1,221** | **0.016** | **43,288** | **0.15** | |

បានឃើញនិងឯកភាព

ជ. ប្រធាននាយកដ្ឋានផែនការនិងស្ថិតិ

ភ្នំពេញ, ថ្ងៃទី ២០ ខែមករា ឆ្នាំ២០១៦

ប្រធានការិយាល័យស្ថិតិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
នាយកដ្ឋានផែនការ និង ស្ថិតិ

# ល្បឿនការងារបច្ចុបន្នេឡើនផលស្រូវរដូវប្រាំងឆ្នាំ២០១៥-២០១៦

(គិតត្រឹមថ្ងៃទី២០ ខែមករា ឆ្នាំ២០១៦)

| ល.រ | រាជធានី-ខេត្ត | ផែនការ (ហ.ត) | ផ្ទៃដីភ្ជួររាស់ | | | | | ផ្ទៃដីសាប (ហ.ត) | ផ្ទៃដីស្ទូង និងព្រោះ (ហត) | | | ភាគរយ | ថ្ងៃខែរាយការណ៍ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | សរុប (ហ.ត) | គោ-ក្របី | | គ្រឿងយន្ត | | | សន្ទូង | ពង្រោះ | សរុប | | |
| | | | | ហ.ត | % | ហ.ត | % | | | | | | |
| 01 | បន្ទាយមានជ័យ | 13,200 | 22,993 | | - | 22,993 | 100.00 | - | - | 22,927 | 22,927 | 173.69 | បញ្ចប់ |
| 02 | បាត់ដំបង | 10,500 | 13,999 | | - | 13,999 | 100.00 | - | - | 13,985 | 13,985 | 133.19 | 18-01-2016 |
| 03 | កំពង់ចាម | 42,000 | 30,539 | 7,945 | 26.02 | 22,594 | 73.98 | 121 | 1,179 | 26,419 | 27,598 | 65.71 | 14-01-2016 |
| 04 | កំពង់ឆ្នាំង | 29,700 | 34,642 | 511 | 1.48 | 34,131 | 98.52 | 517 | 2,832 | 31,293 | 34,125 | 114.90 | 18-01-2016 |
| 05 | កំពង់ស្ពឺ | 550 | - | | - | | - | - | - | - | - | - | |
| 06 | កំពង់ធំ | 36,000 | 43,998 | - | - | 43,998 | 100.00 | 36 | 328 | 43,670 | 43,998 | 122.22 | បញ្ចប់ |
| 07 | កំពត | 7,000 | 9,737 | | - | 9,737 | 100.00 | - | - | 9,737 | 9,737 | 139.10 | បញ្ចប់ |
| 08 | កណ្ដាល | 53,500 | 56,030 | 1,721 | 3.07 | 54,309 | 96.93 | - | - | 54,971 | 54,971 | 102.75 | 19-01-2016 |
| 09 | កោះកុង | - | - | | - | | - | - | - | - | - | - | |
| 10 | ក្រចេះ | 14,000 | 14,302 | 2,856 | 19.97 | 11,446 | 80.03 | 366 | 4,144 | 9,194 | 13,338 | 95.27 | បញ្ចប់ |
| 11 | មណ្ឌលគិរី | - | - | | - | | - | - | - | - | - | - | |
| 12 | ភ្នំពេញ | 1,440 | 1,120 | 419 | 37.41 | 701 | 62.59 | 30 | 190 | 715 | 905 | 62.85 | 19-01-2016 |
| 13 | ព្រះវិហារ | 130 | 19 | | - | 19 | 100.00 | - | - | 15 | 15 | 11.54 | 06-01-2016 |
| 14 | ព្រៃវែង | 75,000 | 95,245 | 668 | 0.70 | 94,577 | 99.30 | - | - | 95,245 | 95,245 | 126.99 | 19-01-2015 |
| 15 | ពោធិសាត់ | 8,300 | 13,863 | | - | 13,863 | 100.00 | - | - | 13,805 | 13,805 | 166.33 | 19-01-2015 |
| 16 | រតនៈគិរី | - | - | | - | | - | - | - | - | - | - | |
| 17 | សៀមរាប | 20,925 | 22,680 | 150 | 0.66 | 22,530 | 99.34 | - | - | 20,985 | 20,985 | 100.29 | បញ្ចប់ |
| 18 | ព្រះសីហនុ | - | - | | - | | - | - | - | - | - | - | |
| 19 | ស្ទឹងត្រែង | 100 | 58 | | - | 58 | 100.00 | - | - | 53 | 53 | 53.00 | 19-01-2016 |
| 20 | ស្វាយរៀង | 17,850 | 19,200 | | - | 19,200 | 100.00 | - | - | 19,168 | 19,168 | 107.38 | 19-01-2016 |
| 21 | តាកែវ | 75,000 | 134,858 | 2,549 | 1.89 | 132,309 | 98.11 | - | - | 91,799 | 91,799 | 122.40 | 18-01-2016 |
| 22 | ឧត្តរមានជ័យ | 600 | 136 | | - | 136 | 100.00 | 4 | 31 | 103 | 134 | 22.33 | 18-01-2016 |
| 23 | កែប | 30 | 40 | 14 | 35.00 | 26 | 65 | - | - | 32 | 32 | 106.67 | បញ្ចប់ |
| 24 | ប៉ៃលិន | 1,000 | 250 | | - | 250 | 100 | - | - | 170 | 170 | 17.00 | 19-01-2016 |
| 25 | ត្បូងឃ្មុំ | 10,500 | 10,375 | 260 | 2.51 | 10,115 | 97.49 | 67 | 670 | 9,705 | 10,375 | 98.81 | បញ្ចប់ |
| សរុប | | 417,325 | 524,084 | 17,093 | 3.26 | 506,991 | 96.74 | 1,141 | 9,374 | 463,991 | 473,365 | 113.43 | |
| តួលេខសប្ដាហ៍មុន | | 417,325 | 512,914 | 16,866 | 3.29 | 496,048 | 96.71 | 1,141 | 9,002 | 450,300 | 459,302 | 110.06 | |
| តួលេខឆ្នាំមុន | | 415,965 | 518,020 | 20,721 | 4.00 | 497,299 | 96.00 | 3,999 | 13,610 | 440,063 | 453,673 | 109.07 | |
| ប្រៀបធៀបឆ្នាំមុន | | 1,360 | 6,064 | -3,628 | -0.74 | 9,692 | 0.74 | -2,858 | -4,236 | 23,928 | 19,692 | 4.36 | |

ភ្នំពេញ, ថ្ងៃទី ២១ ខែមករា ឆ្នាំ២០១៦
ប្រធានការិយាល័យស្ថិតិ

បានឃើញនិងឯកភាព
ក. ប្រធាននាយកដ្ឋានផែនការនិងស្ថិតិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
នាយកដ្ឋានផែនការ និង ស្ថិតិ

# ល្បឿនការងារប្រមូលផលស្រូវរដូវប្រាំងឆ្នាំ ២០១៥-២០១៦

(គិតត្រឹមថ្ងៃទី២០ ខែមករា ឆ្នាំ២០១៦)

| ល.រ | រាជធានី-ខេត្ត | ផ្ទៃដីអនុវត្ត (ហត) | ផ្ទៃដីប្រមូលផល (ហត) | ទិន្នផល (តោន/ហ.ត) | បរិមាណផល (តោន) | ភាគរយ (%) | ថ្ងៃខែរាយការណ៍ |
|---|---|---|---|---|---|---|---|
| 01 | បន្ទាយមានជ័យ | 22,927 | | - | | - | |
| 02 | បាត់ដំបង | 13,985 | | - | | - | |
| 03 | កំពង់ចាម | 27,598 | | - | | - | |
| 04 | កំពង់ឆ្នាំង | 34,125 | | - | | - | |
| 05 | កំពង់ស្ពឺ | - | | - | | - | |
| 06 | កំពង់ធំ | 43,998 | | - | | - | |
| 07 | កំពត | 9,737 | | - | | - | |
| 08 | កណ្ដាល | 54,971 | 2,218 | 4.059 | 9,003 | 4.03 | 19-01-2016 |
| 09 | កោះកុង | - | | - | | - | |
| 10 | ក្រចេះ | 13,338 | 3,334 | 4.186 | 13,956 | 25.00 | 19-01-2016 |
| 11 | មណ្ឌលគិរី | - | | - | | - | |
| 12 | ភ្នំពេញ | 905 | | - | | - | |
| 13 | ព្រះវិហារ | 15 | | - | | - | |
| 14 | ព្រៃវែង | 95,245 | 22,309 | 4.828 | 107,700 | 23.42 | 19-01-2016 |
| 15 | ពោធិ៍សាត់ | 13,805 | 940 | 4.178 | 3,927 | 6.81 | 19-01-2016 |
| 16 | រតនគិរី | - | | - | | - | |
| 17 | សៀមរាប | 20,985 | | - | | - | |
| 18 | ព្រះសីហនុ | - | | - | | - | |
| 19 | ស្ទឹងត្រែង | 53 | | - | | - | |
| 20 | ស្វាយរៀង | 19,168 | 2,218 | 4.059 | 9,003 | 11.57 | 19-01-2016 |
| 21 | តាកែវ | 91,799 | | - | | - | |
| 22 | ឧត្ដរមានជ័យ | 134 | | - | | - | |
| 23 | កែប | 32 | | - | | - | |
| 24 | ប៉ៃលិន | 170 | | - | | - | |
| 25 | ត្បូងឃ្មុំ | 10,375 | 465 | 3.619 | 1,683 | 4.48 | 15-01-2016 |
| សរុប | | **473,365** | **31,484** | **4.614** | **145,272** | **6.65** | |
| តួលេខឆ្នាំ២០១៤-១៥ | | **453,673** | **25,017** | **4.566** | **114,234** | **5.51** | |
| ប្រៀបធៀបឆ្នាំមុន | | **19,692** | **6,467** | **0.048** | **31,038** | **1.14** | |

បានឃើញនិងឯកភាព

ត. ប្រធាននាយកដ្ឋានផែនការនិងស្ថិតិ

ភ្នំពេញ, ថ្ងៃទី ២០ ខែមករា ឆ្នាំ២០១៦

ប្រធានការិយាល័យស្ថិតិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ
នាយកដ្ឋានផែនការនិងស្ថិតិ

# ល្បឿនការងារបច្ចុបង្កើនផលដំណាំរួមផ្សំ និងដំណាំឧស្សាហកម្មរដូវប្រាំងឆ្នាំ២០១៥-២០១៦

(គិតត្រឹមថ្ងៃទី២០ ខែមករា ឆ្នាំ២០១៦)

| ល.រ | រាជធានី-ខេត្ត | ពោត (ហ.ត) | | | | ដំឡូងឈើ (ហ.ត) | | ដំឡូងជ្វា (ហ.ត) | | បន្លែគ្រប់មុខ (ហ.ត) | | សណ្តែកបាយ (ហ.ត) | | សរុបរួម (ហ.ត) | | ភាគរយ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ផែនការ | | អនុវត្ត | | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | % |
| | | សរុប | ក្រហម | សរុប | ក្រហម | | | | | | | | | | | |
| 01 | បន្ទាយមានជ័យ | 50 | - | 143 | - | 180 | 6,395 | - | - | 454 | 1,192 | 300 | 42 | 984 | 7,772 | 789.84 |
| 02 | បាត់ដំបង | 200 | - | 237 | - | 100 | 95 | 300 | 26 | 500 | 559 | 2,500 | 940 | 3,600 | 1,857 | 51.58 |
| 03 | កំពង់ចាម | 1,010 | 150 | 2,011 | 1,067 | 20 | 38 | 760 | 336 | 2,380 | 3,418 | 150 | 560 | 4,320 | 6,363 | 147.29 |
| 04 | កំពង់ឆ្នាំង | 500 | - | 1,090 | - | 300 | 95 | 300 | 239 | 100 | 1,907 | 2,500 | 1,805 | 3,700 | 5,136 | 138.81 |
| 05 | កំពង់ស្ពឺ | 50 | - | - | - | 200 | - | 200 | - | 100 | 82 | 500 | - | 1,050 | 82 | 7.81 |
| 06 | កំពង់ធំ | 200 | - | 242 | - | 200 | 121 | 300 | 64 | - | 369 | 500 | 18 | 1,200 | 814 | 67.83 |
| 07 | កំពត | - | - | - | - | 800 | - | 100 | - | 1,000 | - | 200 | - | 2,100 | - | - |
| 08 | កណ្តាល | 3,000 | - | 3,922 | 3,707 | 300 | 49 | 200 | 86 | 3,000 | 3,596 | 700 | 3,519 | 7,200 | 11,172 | 155.17 |
| 09 | កោះកុង | - | - | - | - | - | - | - | - | - | - | - | - | - | - | - |
| 10 | ក្រចេះ | 500 | - | 6,870 | 6,700 | 100 | - | 100 | 95 | 100 | 607 | 300 | 60 | 1,100 | 7,632 | 693.82 |
| 11 | មណ្ឌលគិរី | - | - | - | - | - | - | - | - | - | - | - | - | - | - | - |
| 12 | ភ្នំពេញ | 285 | - | 60 | - | - | 3 | - | 4 | 600 | 91 | - | 6 | 885 | 164 | 18.53 |
| 13 | ព្រះវិហារ | - | - | - | - | - | - | - | - | - | 304 | - | - | - | 304 | - |
| 14 | ព្រៃវែង | 1,000 | - | 874 | 874 | 100 | 4 | 200 | - | 500 | 681 | 1,200 | 3,228 | 3,000 | 4,787 | 159.57 |
| 15 | ពោធិ៍សាត់ | 200 | - | 181 | 5 | 400 | 1,013 | 350 | 32 | 350 | 395 | 350 | 53 | 1,650 | 1,674 | 101.45 |
| 16 | រតនគិរី | - | - | - | - | - | - | - | - | - | - | - | - | - | - | - |
| 17 | សៀមរាប | 500 | - | 527 | - | 500 | 3,410 | 500 | 250 | 900 | 1,060 | 1,200 | 2,365 | 3,600 | 7,612 | 211.44 |
| 18 | ព្រះសីហនុ | - | - | - | - | - | - | - | - | - | 26 | - | - | - | 26 | - |
| 19 | ស្ទឹងត្រែង | - | - | 161 | - | - | - | - | 25 | 100 | 190 | 100 | 150 | 200 | 526 | 263.00 |
| 20 | ស្វាយរៀង | 100 | 38 | - | - | 100 | 410 | 200 | 102 | 150 | 1,080 | 350 | - | 900 | 1,592 | 176.89 |
| 21 | តាកែវ | - | - | 85 | - | 500 | 44 | 200 | 68 | 800 | 441 | 500 | 64 | 2,000 | 702 | 35.10 |
| 22 | ឧត្តរមានជ័យ | 109 | - | 107 | - | 24 | - | 6 | 23 | - | 118 | 100 | 99 | 239 | 347 | 145 |
| 23 | កែប | - | - | 137 | 19 | 300 | 11 | 100 | 101 | 200 | 121 | - | - | 600 | 370 | 61.67 |
| 24 | ប៉ៃលិន | - | - | - | - | 50 | - | - | - | - | - | 400 | - | 450 | - | - |
| 25 | ត្បូងឃ្មុំ | 2,800 | - | 6,230 | 5,880 | - | 14 | 300 | 415 | 570 | 1,000 | 250 | 547 | 3,920 | 8,206 | 209.34 |
| | សរុប | 10,504 | 188 | 22,877 | 18,252 | 4,174 | 11,702 | 4,116 | 1,866 | 11,804 | 17,237 | 12,100 | 13,456 | 42,698 | 67,138 | 157.24 |
| | តួលេខសប្តាហ៍មុន | 10,504 | 188 | 20,584 | 16,159 | 4,174 | 7,231 | 4,116 | 1,776 | 11,804 | 15,976 | 12,100 | 12,156 | 42,698 | 57,723 | 135.19 |
| | តួលេខឆ្នាំមុន | 10,504 | 188 | 16,357 | 12,284 | 4,174 | 12,535 | 4,116 | 2,077 | 11,804 | 13,075 | 12,100 | 5,735 | 42,698 | 49,779 | 116.58 |
| | ប្រៀបធៀបឆ្នាំមុន | - | - | 6,520 | 5,968 | - | -833 | - | -211 | - | 4,162 | - | 7,721 | - | 17,359 | 40.66 |

| ល.រ | រាជធានី-ខេត្ត | សណ្តែកដី (ហ.ត) | | សណ្តែកសៀង (ហ.ត) | | ល្ង (ហ.ត) | | អំពៅ (ហ.ត) | | ក្រចៅ (ហ.ត) | | ថ្នាំជក់ (ហ.ត) | | សរុបរួម (ហ.ត) | | ភាគរយ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | (%) |
| 01 | បន្ទាយមានជ័យ | - | - | - | - | - | - | - | 129 | - | - | - | - | - | 129 | - |
| 02 | បាត់ដំបង | 100 | 40 | - | - | 160 | 116 | 27 | 24 | | - | | - | 287 | 180 | 62.72 |
| 03 | កំពង់ចាម | 790 | 701 | - | - | 30 | - | 360 | 296 | - | - | 3,380 | 3,544 | 4,560 | 4,541 | 99.58 |
| 04 | កំពង់ឆ្នាំង | 100 | 92 | - | - | 100 | 792 | 100 | 61 | - | 8 | 50 | 68 | 350 | 1,021 | 291.71 |
| 05 | កំពង់ស្ពឺ | - | - | - | - | - | - | 120 | - | - | - | - | - | 120 | - | - |
| 06 | កំពង់ធំ | - | 116 | 1,000 | - | - | 7 | - | 2 | - | - | - | - | 1,000 | 125 | 12.50 |
| 07 | កំពត | 250 | - | - | - | - | - | 200 | - | - | - | 100 | - | 550 | - | - |
| 08 | កណ្តាល | 500 | 8 | - | 25 | - | 18 | 800 | 537 | - | 11 | - | - | 1,300 | 599 | 46.08 |
| 09 | កោះកុង | - | - | - | - | - | - | - | - | | - | - | - | - | - | - |
| 10 | ក្រចេះ | 100 | 182 | - | - | 100 | - | 50 | 112 | | - | 50 | 1,300 | 300 | 1,594 | 531.33 |
| 11 | មណ្ឌលគីរី | - | - | - | - | - | - | - | - | - | - | - | - | - | - | - |
| 12 | ភ្នំពេញ | - | - | - | - | - | - | - | 7 | | - | | - | - | 7 | - |
| 13 | ព្រះវិហារ | - | - | - | - | - | - | - | - | - | - | - | - | - | - | - |
| 14 | ព្រៃវែង | 400 | 248 | - | - | 200 | 2 | 100 | 275 | - | - | - | - | 700 | 525 | 75.00 |
| 15 | ពោធិ៍សាត់ | 600 | 26 | - | 82 | 200 | 196 | 1,000 | 66 | - | - | - | - | 1,800 | 370 | 20.56 |
| 16 | រតនគីរី | - | - | - | - | - | - | - | - | | - | | - | - | - | - |
| 17 | សៀមរាប | - | - | - | 630 | 800 | 15 | 400 | 136 | 80 | - | - | - | 1,280 | 781 | 61.02 |
| 18 | ព្រះសីហនុ | - | - | - | - | - | - | - | - | | - | - | - | - | - | - |
| 19 | ស្ទឹងត្រែង | 200 | 65 | - | - | - | - | - | - | | - | 30 | - | 230 | 65 | - |
| 20 | ស្វាយរៀង | - | - | - | - | - | - | 50 | 201 | | - | - | - | 50 | 201 | 402.00 |
| 21 | តាកែវ | - | 22 | - | - | - | - | 100 | 50 | - | - | - | - | 100 | 72 | 72.00 |
| 22 | ឧត្តរមានជ័យ | 184 | 75 | 173 | - | 1,199 | 55 | 408 | 29 | - | - | - | - | 1,964 | 159 | 8 |
| 23 | កែប | 100 | 34 | - | - | - | - | - | 6 | | - | | - | 100 | 40 | 40.00 |
| 24 | ប៉ៃលិន | 50 | - | - | - | - | - | - | - | | - | | - | 50 | - | - |
| 25 | ត្បូងឃ្មុំ | 250 | 124 | - | - | - | - | 20 | 20 | | - | 5,320 | 1,230 | 5,590 | 1,374 | 24.58 |
| | សរុប | 3,624 | 1,733 | 1,173 | 737 | 2,789 | 1,201 | 3,735 | 1,951 | 80 | 19 | 8,930 | 6,142 | 20,331 | 11,783 | 57.96 |
| | តួលេខសប្តាហ៍មុន | 3,624 | 1,701 | 1,173 | 737 | 2,789 | 1,196 | 3,735 | 1,706 | 80 | 19 | 8,930 | 5,563 | 20,331 | 10,922 | 53.72 |
| | តួលេខឆ្នាំមុន | 3,624 | 1,857 | 1,173 | 22 | 2,789 | 1,185 | 3,735 | 1,442 | - | 22 | 8,930 | 7,613 | 20,251 | 12,141 | 59.95 |
| | ប្រៀបធៀបឆ្នាំមុន | - | -124 | - | 715 | - | 16 | - | 509 | 80 | -3 | - | -1,471 | 80 | -358 | -2.00 |

ភ្នំពេញ, ថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៦

ប្រធានការិយាល័យស្ថិតិ

បានឃើញ និងឯកភាព

ក. ប្រធាននាយកដ្ឋានផែនការ និងស្ថិតិ